ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......សហវ.

**សារាចរណែនាំ**

**ស្តីពី**

**ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ**
**សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៣៥៤ អនក្រ.បក ចុះថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ និងអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៤។ ដើម្បីឱ្យ ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ មានដំណើរការប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងសម្រេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ដូចតទៅ÷

**ក. អំពីការធ្វើប្រតិភូកម្មថវិកា និងអាណាប័កផ្ទេរសិទ្ធិ**

ក្រោយពេលទទួលបានប្រកាសស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូល និងការបែងចែកឥណទានចំណាយថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷

- អភិបាលនៃគណៈអភិបាលរាជធានី ត្រូវចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឱ្យអភិបាលនៃគណៈអភិបាលខណ្ឌចំណុះរាជធានី ដើម្បីអនុវត្តថវិកា ដោយផ្អែកលើសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ ដែលរដ្ឋបាលខណ្ឌបានរៀបចំរួច និងបានដាក់បញ្ចូលក្នុងសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ របស់រដ្ឋបាលរាជធានី។

- អភិបាលនៃគណៈអភិបាលរាជធានី ត្រូវចេញសេចក្តីសម្រេចធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឱ្យចៅសង្កាត់នីមួយៗចំណុះរាជធានី ដើម្បីអនុវត្តថវិកា ដោយផ្អែកលើសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ដែលរដ្ឋបាលសង្កាត់នីមួយៗ បានរៀបចំរួច និងត្រូវបានត្រួតពិនិត្យនីត្យានុកូលភាព និងបញ្ជាក់អនុលោមភាពទទួលស្គាល់ដោយអភិបាលនៃគណៈអភិបាលរាជធានី។

- អភិបាលនៃគណៈអភិបាលក្រុង ត្រូវចេញសេចក្ដីសម្រេចធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឱ្យចៅសង្កាត់នីមួយៗចំណុះក្រុង ដើម្បីអនុវត្តថវិកា ដោយផ្អែកលើសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ ដែលរដ្ឋបាលសង្កាត់នីមួយៗ បានរៀបចំរួច និងត្រូវបានត្រួតពិនិត្យនីត្យានុកូលភាព និងបញ្ជាក់អនុលោមភាពទទួលស្គាល់ដោយអភិបាលនៃគណៈអភិបាលខេត្ត។

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលជាអាណាប័កដើមខ្សែនៃកញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលរដ្ឋបាលរាជធានី ខេត្ត ត្រូវចេញដីកាធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឱ្យប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត និងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស ដើម្បីបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយក្នុងនាមអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ផ្អែកលើសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីមានការបន្ថែមឥណទានថវិកាក្នុងឆ្នាំអនុវត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្តមិនចាំបាច់ចេញដីកាធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិម្ដងទៀតនោះទេ។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុងត្រូវផ្ញើសេចក្ដីសម្រេច ឬដីកាធ្វើប្រតិភូកម្មចំណូល ចំណាយថវិកា និងអាណាប័កផ្ទេរសិទ្ធិទៅឲ្យខណ្ឌ សង្កាត់នីមួយៗ និងមន្ទីរសុខាភិបាលរាជធានី ខេត្ត ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ០១ច្បាប់ និងរតនាគាររាជធានី ខេត្ត ០១ច្បាប់(ច្បាប់ដើម)។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះថវិកាប្រតិភូកម្មដែលអនុវត្តដោយអាណាប័កផ្ទេរសិទ្ធិ។

- អភិបាលនៃគណៈអភិបាល ក្រុង ស្រុក ជាអាណាប័កដើមខ្សែ និងអភិបាលនៃគណៈអភិបាលខណ្ឌ ជាអាណាប័កផ្ទេរសិទ្ធិ នៃកញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ក្នុងការបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយថវិកាក្នុងវង្វង់ឥណទានថវិកាដូចមានរាយលម្អិតក្នុងសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ខ.អំពីចំណូល

### ខ.១.ចំណូលសារពើពន្ធ

រដ្ឋបាលរាជធានី ខេត្ត ត្រូវសហការជាមួយមន្ត្រីពន្ធដារ ដើម្បីជំរុញ និងតាមដានការអនុវត្តគោលនយោបាយ និងនីតិវិធីប្រមូលចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតឱ្យប្រមូលសម្រាប់ជាគុណប្រយោជន៍នៃថវិការដ្ឋបាលរាជធានី ខេត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន និងត្រូវរួមចំណែកដាក់ចេញនូវវិធានការជាក់ស្ដែងសម្រាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវឱ្យអ្នកជាប់ពន្ធបង់ពន្ធបានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា។ ទន្ទឹមនឹងនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់មន្ត្រីទទួលបន្ទុក ប្រមូលទិន្នន័យស្ថិតិ និងកម្រងព័ត៌មាន ដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធដារសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត ដើម្បីជាមូលដ្ឋានតាមដានត្រួតពិនិត្យ និងជួយដល់មន្ត្រីពន្ធដារ ក្នុងការប្រមូលចំណូល និងធ្វើជាឯកសារយោងក្នុងការរៀបចំគម្រោងចំណូលសារពើពន្ធប្រចាំឆ្នាំនីមួយៗ។

## ខ.២.ចំណូលមិនមែនសារពើពន្ធ

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នីមួយៗ ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវ និងកំណត់មុខសញ្ញាចំណូលដែលច្បាប់បានអនុញ្ញាតឱ្យប្រមូលតាមមុខសញ្ញាចំណូលមិនមែនសារពើពន្ធ បង់ចូលគណនីប្រាក់បញ្ញើនៅរតនាគាររាជធានី ខេត្តឱ្យអស់ មិនត្រូវទុកចំណូលខ្លះ សម្រាប់ចំណាយដោយឡែកក្រៅពីគម្រោងចំណាយប្រចាំឆ្នាំឡើយ។

១.ចំណូលដែលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈផ្សេងៗទៀត តាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័ននានា នៅអង្គភាពច្រកចេញ ចូលតែមួយរាជធានី ខេត្ត និងនៅមន្ទីរជំនាញរាជធានី ខេត្ត ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញ ចូលតែមួយរាជធានី ខេត្ត និងសារាចរលេខ ០០៦ សហវ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញ ចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត។

២.ចំពោះចំណូលមិនមែនសារពើពន្ធ ដែលត្រូវប្រមូលពីកម្រៃសេវារដ្ឋបាល ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមដីកាកំណត់តម្លៃសេវារដ្ឋបាលជាក់ស្តែង សម្រាប់ប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី ដោយផ្អែកតាមស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ស្របតាមខ្លឹមសារនៃប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រងនិងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៣.ចំពោះចំណូលមិនមែនសារពើពន្ធផ្សេងៗទៀតដូចជា÷

- ចំណូលពីការបែងចែកចំណូលសួយសារលើតម្លៃផលិតផលរ៉ែសំណង់ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសអន្តរក្រសួងលេខ ៧៦០ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីអត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ។ ចំពោះប្រាក់រង្វាន់លើកទឹកចិត្តមន្ត្រីរាជការនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសអន្តរក្រសួងលេខ ៧៦១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការប្រើប្រាស់ថវិកាសម្រាប់ប្រាក់រង្វាន់លើកទឹកចិត្ត និងពង្រឹងយន្តការនៃការកៀរគរ និងប្រមូលចំណូលសួយសារផលិតផលរ៉ែ។
- ចំណូលសម្បទាននេសាទ របស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានផ្ទេរ និងកត់ត្រាជាចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ១០០% សម្រាប់ជាគុណប្រយោជន៍ដល់ថវិការាជធានី ខេត្ត។
- ចំណូលពីកម្រៃសេវាថែទាំអ្នកជំងឺនៅតាមមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ស្រុក និងមណ្ឌលសុខភាពដែលប្រមូលបាន ត្រូវបង់ចំណែក ១% សម្រាប់ជាគុណប្រយោជន៍ដល់ថវិការាជធានី ខេត្ត និងចំណូលផ្សេងៗទៀតក្រៅពីចំណូលកម្រៃសេវាថែទាំអ្នកជំងឺដែលមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ស្រុក និងមណ្ឌលសុខភាពប្រមូលបានត្រូវបង់ចំណែក ៧៥% សម្រាប់ជាគុណប្រយោជន៍ដល់ថវិការាជធានី ខេត្ត ដោយត្រូវអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល។

- ចំណូលបានពីកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន ត្រូវអនុវត្តតាមខ្លឹមសារជំពូកទី៥ មាត្រា១៦ នៃអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងចំណូលពីកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យ និងផលិតផលមានដើមកំណើតពីសត្វរាល់ការនាំចូល នាំចេញ ឆ្លងកាត់ និងដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ ត្រូវអនុវត្តតាមខ្លឹមសារ នៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ។

ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ ស្ថិតក្នុងលក្ខខណ្ឌដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើឱ្យមានតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលឱ្យបានត្រឹមត្រូវតាមការកំណត់ដូចមានចែងក្នុងកិច្ចសន្យា។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្ដាកផ្ដល់សេវារដ្ឋបាលមួយចំនួន ចំពោះការបំពេញបែបបទធ្វើអាជីវកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួងលេខ ១៤៣៨២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១០០ សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការផ្អាកការផ្ដល់សេវារដ្ឋបាលមួយចំនួនរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ២.៣. ចំណូលឧបត្ថម្ភធនពីថវិកាជាតិ

ការបំពេញតុល្យភាពឧបត្ថម្ភធនពីថវិកាជាតិជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទោះបីរដ្ឋបាលនីមួយៗ បានកត់ត្រាតួលេខចំណូលឧបត្ថម្ភធនពីថវិកាជាតិនៅក្នុងគម្រោងថវិការបស់រដ្ឋបាលសាមីក៏ដោយ ក៏មិនមានន័យថា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងទទួលបានឧបត្ថម្ភធនពីថវិកាជាតិតាមចំនួននោះទេ។ ចំណូលឧបត្ថម្ភធនពីថវិកាជាតិសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវផ្ដល់ជូនដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតុល្យភាពថវិកាជាតិ និងទៅតាមការអនុវត្តចំណូល ចំណាយថវិកាជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ។

### ២.៣.១. ចំណូលឧបត្ថម្ភធនពីថវិកាជាតិប្រចាំត្រីមាស

#### ១. ការឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត

**១.១.ការឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសដល់រដ្ឋបាលរាជធានី ខេត្ត÷** នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនជូនរដ្ឋបាលរាជធានី ខេត្ត ដោយមិនចាំបាច់មានការស្នើសុំទេ។ សម្រាប់អាណត្តិចំណាយបើកផ្ដល់ប្រាក់បៀវត្ស ក្នុងករណីគណនីប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត ពុំមានសមតុល្យគ្រប់គ្រាន់ រតនាគាររាជធានី ខេត្ត ត្រូវផ្ដល់បុរេប្រទានសមតុល្យគណនីប្រាក់បញ្ញើរាជធានី ខេត្ត ដើម្បីទូទាត់អាណត្តិ។ នៅពេលមានសមតុល្យក្នុងគណនីប្រាក់បញ្ញើ រតនាគាររាជធានី ខេត្ត ត្រូវកាត់កងជម្រះបញ្ជីជាមួយបុរេប្រទានសមតុល្យ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសំណើស្នើសុំថវិកាឧបត្ថម្ភតុល្យភាពពីថវិកាជាតិមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅដើមខែនៃចុងត្រីមាសមុន ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូលជាក់ស្តែងដូចមានគំរូតារាងឧបសម្ព័ន្ធ “ក១”
- របាយការណ៍អនុវត្តចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្តដូចមានគំរូតារាងឧបសម្ព័ន្ធ “ក១.១”

- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ ដែលមានការបែងចែកតាមខែនីមួយៗ ដោយផ្អែកលើរបាយការណ៍ប៉ាន់ស្មានចំណូលរបស់សាខាពន្ធដារខេត្ត និងឯកសារគាំទ្រនានា ដូចមានគំរូតារាងឧបសម្ព័ន្ធ "ខ១"
- របាយការណ៍អនុវត្តចំណាយជាក់ស្តែងដូចមានគំរូតារាងឧបសម្ព័ន្ធ "ក២"
- លិខិតសន្យាចំណាយថវិកា សលាកបត្រកត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ អាណត្តិបើកប្រាក់ (ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់) ដូចមានគំរូតារាងឧបសម្ព័ន្ធ "ខ២"។

**១.២. ការឧបត្ថម្ភធនកញ្ចប់ថវិកាពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលរបស់ក្រសួងសុខាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត÷** នៅដើមឆ្នាំថវិកា ផ្អែកតាមប្រកាសស្តីពីការបែងចែកឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល និងសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ របស់មន្ទីរសុខាភិបាល និងទីភ្នាក់ងារប្រតិបត្តិការពិសេសរាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់តែមួយលើកឧបត្ថម្ភធនជូនរដ្ឋបាលរាជធានី ខេត្ត ១០០% នៃឥណទានថវិកាដើមឆ្នាំរបស់មន្ទីរសុខាភិបាល និងទីភ្នាក់ងារប្រតិបត្តិការពិសេសរាជធានី ខេត្ត។ រដ្ឋបាលរាជធានី ខេត្ត នៅពេលទទួលបានអាណត្តិបើកប្រាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឧបត្ថម្ភធនថវិកាជូនមន្ទីរសុខាភិបាល និងទីភ្នាក់ងារប្រតិបត្តិការពិសេសរាជធានី ខេត្ត ត្រូវកត់ត្រាចំណូលក្នុងអនុគណនី ៧៥០១៦ (ឧបត្ថម្ភធនពីក្រសួង ស្ថាប័នសម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ)។

**១.៣. ការឧបត្ថម្ភធនកញ្ចប់ថវិកាការិយាល័យជំនាញទាំង ២០វិស័យជូនរដ្ឋបាលខណ្ឌ÷** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនថវិកាជូនរដ្ឋបាលខណ្ឌ តាមរយៈរដ្ឋបាលរាជធានីភ្នំពេញ ជា ០៤ (បួន) លើក ប្រចាំត្រីមាសនីមួយៗ ដោយមិនចាំបាច់មានការស្នើសុំនោះទេ។

រដ្ឋបាលរាជធានីភ្នំពេញ នៅពេលទទួលបានអាណត្តិបើកប្រាក់ពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការឧបត្ថម្ភធនថវិកាប្រចាំត្រីមាសនីមួយៗ ជូនរដ្ឋបាលខណ្ឌ ត្រូវរួសរាន់បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនជូនរដ្ឋបាលខណ្ឌ ដោយប្រើប្រាស់អនុគណនី ៦៥០១២ (ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ)។

**១.៤. ការឧបត្ថម្ភធនកញ្ចប់ថវិកាសម្រាប់អនុវត្តការប្រគល់មុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលខណ្ឌ÷** នៅដើមឆ្នាំថវិកា ផ្អែកតាមប្រកាសស្តីពីការបែងចែកឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដូចរាយលម្អិតក្នុងសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនតែមួយលើក ជូនរដ្ឋបាលរាជធានីភ្នំពេញ ១០០% នៃឥណទានថវិកា។

រដ្ឋបាលរាជធានីភ្នំពេញ នៅពេលទទួលបានអាណត្តិបើកប្រាក់ពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការឧបត្ថម្ភធនថវិកាជូនរដ្ឋបាលខណ្ឌ ត្រូវកត់ត្រាចំណូលក្នុងអនុគណនី ៧៥០១៦ (ឧបត្ថម្ភធនពីក្រសួង ស្ថាប័នសម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ) និងត្រូវរួសរាន់បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនជូនរដ្ឋបាលខណ្ឌ ដោយប្រើប្រាស់អនុគណនី ៦៥០១៦ (ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ)។

រដ្ឋបាលខណ្ឌ នៅពេលទទួលបានអាណត្តិបើកប្រាក់ពីរដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការឧបត្ថម្ភធនថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ត្រូវកត់ត្រាចំណូលក្នុងអនុគណនី ៧៥០១៦ (ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ)។

**២.ការឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក**

**២.១.ការឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសដល់រដ្ឋបាលក្រុង ស្រុក÷** នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនជូនរដ្ឋបាលក្រុង ស្រុកដោយមិនចាំបាច់មានការស្នើសុំនោះទេ។ សម្រាប់អាណត្តិចំណាយបើកផ្តល់ប្រាក់បៀវត្ស ក្នុងករណីគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុកពុំមានសមតុល្យគ្រប់គ្រាន់ រតនាគាររាជធានី ខេត្តត្រូវផ្តល់បុរេប្រទានសមតុល្យគណនីប្រាក់បញ្ញើក្រុង ស្រុក ដើម្បីទូទាត់អាណត្តិ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ នៅដើមខែនៃចុងត្រីមាសមុន រដ្ឋបាលក្រុង ស្រុកត្រូវរៀបចំសំណើស្នើសុំថវិកាឧបត្ថម្ភតុល្យភាពពីថវិកាជាតិមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលខេត្តសាមី ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូលជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុកដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១"
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ដោយមានបែងចែកតាមខែនីមួយៗដូចមានគំរូតារាងឧបសម្ព័ន្ធ "ខ១"
- របាយការណ៍អនុវត្តចំណាយជាក់ស្តែងដូចមានគំរូតារាងឧបសម្ព័ន្ធ "ក២"
- លិខិតសន្យាចំណាយថវិកា សលាកបត្រកត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ អាណត្តិបើកប្រាក់ (ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់មកនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់) ដូចមានគំរូតារាងឧបសម្ព័ន្ធ "ខ២" ជូនភ្ជាប់មកជាមួយ។

**២.២.ការឧបត្ថម្ភធនពីរដ្ឋបាលខេត្ត នូវចំណូលពីការចែករំលែក ៥% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត ជូនរដ្ឋបាលក្រុង ស្រុកសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន÷**

នៅដើមឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំប្រកាសស្តីពីការបន្ថែមឥណទានជូនរដ្ឋបាលខេត្តដែលធានាដោយប្រភពអតិរេកថវិការាជធានី ខេត្ត និងរៀបចំប្រកាសស្តីពីការបន្ថែមឥណទានជូនរដ្ឋបាលក្រុង ស្រុកដែលធានាដោយប្រភពឧបត្ថម្ភធនពីរដ្ឋបាលរាជធានី ខេត្ត។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនជូនរដ្ឋបាលខេត្ត ជា ០៤ (បួន) លើកប្រចាំត្រីមាសនីមួយៗ ដោយមិនចាំបាច់មានការស្នើសុំនោះទេ។ រដ្ឋបាលខេត្តនៅពេលទទួលបានអាណត្តិបើកប្រាក់ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឧបត្ថម្ភតុល្យភាពថវិកាប្រចាំត្រីមាសនីមួយៗ ជូនរដ្ឋបាលក្រុង ស្រុក សម្រាប់ចំណាយលើការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលក្រុង ស្រុកសាមី រដ្ឋបាលខេត្តត្រូវរួសរាន់បោះផ្សាយអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាជូនរដ្ឋបាលក្រុង ស្រុក ដោយប្រើប្រាស់អនុគណនី ៦៥០១២ (ឧបត្ថម្ភធន ដល់ក្រុង ស្រុក ខណ្ឌ)។

**២.៣.ការឧបត្ថម្ភកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានជូនរដ្ឋបាលក្រុង÷** នៅដើមឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំប្រកាសស្តីពីការបន្ថែមឥណទានជូនរដ្ឋបាលក្រុងគោលដៅទាំង៣១ ដែលធានាដោយប្រភពឧបត្ថម្ភធនពីរាជធានី ខេត្ត។ នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់គោលការណ៍ជូនរដ្ឋបាលខេត្តដើម្បីឧបត្ថម្ភតុល្យភាពថវិកាសេវាអនាម័យបរិស្ថានជូនរដ្ឋបាលក្រុងគោលដៅទាំង៣១ ដោយមិនចាំបាច់មានការស្នើសុំនោះទេ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ នៅដើមខែនៃចុងត្រីមាសមុន រដ្ឋបាលក្រុងត្រូវរៀបចំសំណើស្នើសុំឧបត្ថម្ភតុល្យភាពថវិកាសេវាអនាម័យបរិស្ថានមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈមន្ទីរបរិស្ថានខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូល ចំណាយប្រចាំខែអំពីសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ និងលទ្ធផលការងារដែលសម្រេចបាន
- របាយការណ៍ប៉ាន់ស្មានចំណូល ចំណាយប្រចាំត្រីមាសបន្ទាប់ ដោយមានការបែងចែកតាម ខែនីមួយៗ សម្រាប់ការអនុវត្តសេវាអនាម័យបរិស្ថានរួមទាំងឯកសារគាំទ្រ ដូចជាសេចក្តីចម្លងកិច្ចសន្យារវាងរដ្ឋបាលក្រុង និងដៃគូផ្តល់សេវាអនាម័យបរិស្ថាន និងផែនការសកម្មភាពការងារសេវាអនាម័យបរិស្ថានគ្រប់គ្រងសំណល់រឹង រាវ។

ផ្អែកលើគោលការណ៍ឧបត្ថម្ភតុល្យភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលខេត្ត ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ផ្ទេរឧបត្ថម្ភធនឥណទានថវិកាពីអនុគណនី ៦៥០១២ (ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ) ជូនរដ្ឋបាលក្រុងគោលដៅនៃខេត្តនីមួយៗ។

**២.៤.ការឧបត្ថម្ភធនកញ្ចប់ថវិកាសម្រាប់អនុវត្តការប្រគល់មុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក** ÷ នៅដើមឆ្នាំថវិកា ផ្អែកតាមប្រកាសស្តីពីការបែងចែកឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដូចរាយលម្អិតក្នុងសៀវភៅគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនតែមួយលើក ជូនរដ្ឋបាលក្រុង ស្រុក ១០០% នៃឥណទានថវិកា។ រដ្ឋបាលក្រុង ស្រុកនៅពេលទទួលបានអាណត្តិបើកប្រាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឧបត្ថម្ភធនថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ត្រូវកត់ត្រាចំណូលក្នុងអនុគណនី ៧៥០១៦ (ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ)។

**៣.ការឧបត្ថម្ភធនដល់រដ្ឋបាលឃុំ សង្កាត់**

**៣.១.ការឧបត្ថម្ភធនដល់រដ្ឋបាលឃុំ សង្កាត់ពីមូលនិធិឃុំ សង្កាត់**÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភថវិកាជូនរដ្ឋបាលឃុំ សង្កាត់ជា ០៤ (បួន) លើក÷

- លើកទី១ ÷ នៅដើមត្រីមាសទី១ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី២ ÷ នៅដើមត្រីមាសទី២ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី៣ ÷ នៅដើមត្រីមាសទី៣ ផ្ទេរជូន៤០% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី៤ ÷ នៅដើមត្រីមាសទី៤ ផ្ទេរជូន១០% នៃចំនួនធនធានវិភាជន៍សរុប។

**៣.២.ការឧបត្ថម្ភធន ពីការផ្ទេរធនធានបន្ថែម ១% នៃចំណូលចរន្តថវិការដ្ឋ ជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន**÷ យោងមាត្រា៧ នៃអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធន ជូនរដ្ឋបាលឃុំ សង្កាត់ នឹងផ្ទេរដោយត្រង់ចូលគណនីប្រាក់បញ្ញើរបស់ឃុំ សង្កាត់ ជា ០៤(បួន)លើក÷

- លើកទី១ ÷ នៅដើមត្រីមាសទី១ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី២ ÷ នៅដើមត្រីមាសទី២ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី៣ ÷ នៅដើមត្រីមាសទី៣ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី៤ ÷ នៅដើមត្រីមាសទី៤ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប។

**៣.៣.ការឧបត្ថម្ភពីរដ្ឋបាលរាជធានី ខេត្ត នូវចំណូលពីការចែករំលែក ៦% នៃចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ជូនរដ្ឋបាលឃុំ សង្កាត់ (មិនរួមបញ្ចូលសង្កាត់ចំណុះរាជធានី) សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន÷** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនថវិកាជូនរដ្ឋបាលឃុំ សង្កាត់ ជា ០៤ (បួន) លើក តាមរយៈរដ្ឋបាលខេត្តសាមី÷

- លើកទី១ ÷ នៅដើមត្រីមាសទី១ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី២ ÷ នៅដើមត្រីមាសទី២ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី៣ ÷ នៅដើមត្រីមាសទី៣ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប
- លើកទី៤ ÷ នៅដើមត្រីមាសទី៤ ផ្ទេរជូន២៥% នៃចំនួនធនធានវិភាជន៍សរុប។

នៅដើមឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំប្រកាសស្តីពីការបន្ថែមឥណទានជូនរដ្ឋបាលខេត្ត ដែលធានាដោយប្រភពអតិរេកថវិការាជធានី ខេត្ត ។ រដ្ឋបាលខេត្ត នៅពេលដែលទទួលបានអាណត្តិបើកប្រាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឧបត្ថម្ភគុលុប្បភាពថវិកាប្រចាំត្រីមាសនីមួយៗ ជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយលើការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់សាមី រដ្ឋបាលខេត្តត្រូវរួសរាន់បោះផ្សាយអាណត្តិបើកប្រាក់ផ្ទេរឥណទានថវិកាជូនរដ្ឋបាលឃុំ សង្កាត់ ដោយប្រើប្រាស់អនុគណនី ៦៥០១៣ (ឧបត្ថម្ភធនដល់ឃុំ សង្កាត់)។

រតនាគាររាជធានី ខេត្ត ដែលជាគណនេយ្យករសាធារណៈ និងជាគណនេយ្យករមុខការ នៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងអំពីស្ថានភាពគណនីប្រាក់បញ្ញើនៅរៀងរាល់ដើមសប្តាហ៍នីមួយៗ ដល់ថ្នាក់រដ្ឋបាលទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ.៣.២.ការឧបត្ថម្ភធនពីថវិការាជធានីជូនរដ្ឋបាលខណ្ឌ**

រដ្ឋបាលរាជធានី ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធន ជូនរដ្ឋបាលខណ្ឌប្រចាំត្រីមាសនីមួយៗ ដោយប្រើប្រាស់អនុគណនី ៦៥០១២ (ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ)។ នៅដើមត្រីមាសទី១ រដ្ឋបាលរាជធានី ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនជូនរដ្ឋបាលខណ្ឌ ដោយមិនចាំបាច់មានការស្នើសុំទេ។ ដោយឡែក សម្រាប់ត្រីមាសទី២ ទី៣ និងទី៤ នៅដើមខែនៃចុងត្រីមាសមុន រដ្ឋបាលខណ្ឌ ត្រូវរៀបចំសំណើស្នើសុំថវិកាឧបត្ថម្ភគុលុប្បភាពមករដ្ឋបាលរាជធានីភ្នំពេញ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- របាយការណ៍អនុវត្តចំណូលជាក់ស្តែងរបស់រដ្ឋបាលខណ្ឌដូចមានគំរូតារាងឧបសម្ព័ន្ធ “ក១”
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ដោយមានបែងចែកតាមខែនីមួយៗ ដោយភ្ជាប់នូវឯកសារសម្រាប់គាំទ្រនានាដូចមានគំរូតារាងឧបសម្ព័ន្ធ “ខ១”
- របាយការណ៍អនុវត្តចំណាយជាក់ស្តែងដូចមានគំរូតារាងឧបសម្ព័ន្ធ “ក២”
- លិខិតសន្យាចំណាយថវិកា សលាកបត្រកត់ត្រាចំណាយ និងត្រួតពិនិត្យហិរញ្ញវត្ថុ អាណត្តិបើកប្រាក់ (ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់មកនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់)ដូចមានគំរូតារាងឧបសម្ព័ន្ធ “ខ២” ជូនភ្ជាប់មកជាមួយ។

## គ.អំពីចំណាយ

### គ.១.ចំណាយចរន្ត

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ទៅតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដូចគ្នានៃចំណាយថវិកាជាតិដែរពោលគឺ៖

**គ.១.១. ចំណាយបន្ទុកបុគ្គលិក៖** ត្រូវជំរុញអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ និងត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់ ដោយផ្អែកលើតារាងទូទាត់បៀវត្សរបស់ក្រសួងមុខងារសាធារណៈ ដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខណ្ឌ និងកាំប្រាក់។ ជាមួយគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបើកបៀវត្សជូនមន្ត្រីរាជការ មន្ត្រីសាធារណៈ សមាជិកក្រុមប្រឹក្សា និងមន្ត្រីភូមិ រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ តាមខ្លឹមសារនៃសារាចរលេខ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល មន្ត្រីសាធារណៈផ្សេងទៀត។

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត ដូចខាងក្រោម៖

- ចំពោះបៀវត្សមូលដ្ឋានមន្ត្រីរាជការស៊ីវិល ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ នៃព្រះរាជាណាចក្រកម្ពុជា។
- ចំពោះប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យ ស្តីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា។
- ចំពោះប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ចំពោះប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យ ស្តីពីការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។
- ចំពោះប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ ២៧៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដំឡើងប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារ និងកូនឃោធិន នៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។
- ចំពោះប្រាក់ឧបត្ថម្ភមាតុភាព និងប្រាក់ឧបត្ថម្ភបុណ្យសព ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព។

- ចំពោះប្រាក់ឧបត្ថម្ភជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ទទួលបានប្រចាំខែក្នុងមួយនាក់ចំនួន ១លានរៀល(មួយលានរៀល) ស្របតាមខ្លឹមសារប្រការ ១៥ នៃប្រកាសអន្តរក្រសួងលេខ ០០២ សហវ.ប្រក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ស្តីពីការជ្រើសរើស និងការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។

- ចំពោះប្រាក់ឧបត្ថម្ភជូនក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តស្របតាមប្រកាសលេខ ២១៧៥ ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១ ស្តីពីក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត និងលិខិតលេខ ១០២៨ សជណ.មយ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី រួមមានខ្លឹមសារ (១)រៀបចំក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្តចំនួនចាប់ពី ២នាក់ ដល់ ៤នាក់ និង(២)ប្រើប្រាស់ថវិការាជធានី ខេត្តដើម្បីជួយឧបត្ថម្ភជូនក្រុមមេធាវី ក្នុងចំនួនចន្លោះពី ១លានរៀល (មួយលានរៀល) ទៅ ១,២លានរៀល(មួយលានពីរសែនរៀល) ក្នុងម្នាក់ ក្នុងមួយខែ។ រដ្ឋបាលរាជធានី ខេត្ត ត្រូវបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនក្រុមមេធាវីរាជធានី ខេត្ត តាមប្រព័ន្ធធនាគារ និងប្រើប្រាស់អនុគណនី ៦១០៩១(ភ្នាក់ងារជាតិជាប់កិច្ចសន្យា)។

- ចំពោះការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈ មានជាអាទិ៍ បុព្វលាភ លាភការ ប្រាក់បំណាច់ ប្រាក់បេសកកម្ម ប្រាក់សង្គមកិច្ច ប្រាក់ឧបត្ថម្ភ ប្រាក់បន្ថែមម៉ោង ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ប្រាក់ឧបត្ថម្ភផ្សេងៗទៀត ដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈនៅធនាគារ ត្រូវអនុវត្តតាមខ្លឹមសារអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ០៩ សរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីនីតិវិធីនៃការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈ។

**គ.១.២.ចំណាយរដ្ឋទេយ្យបុរេប្រទាន÷** គឺជាចំណាយតូចតាច ចំណាយចាំបាច់ និងចំណាយជាប្រចាំ ត្រូវអនុវត្តតាមរដ្ឋទេយ្យបុរេប្រទាន ដែលកំណត់ដោយដីការបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់។ ការចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ៥៤៨ សហវ.ប្រក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**គ.១.៣.ចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន÷** គឺជាចំណាយអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបេឡាឡើងវិញ តាមសំណើស្នើសុំបើកប្រាក់របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ៥៥៨ សហវ.ប្រក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ៥៥៩ សហវ.ប្រក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**គ.១.៤ ចំណាយចរន្តផ្សេងៗទៀត÷** ត្រូវអនុវត្តតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ក្រោយពេលដែលទំនិញ ឬសេវានានា ត្រូវបានប្រគល់ទទួលរួចរាល់ហើយ។

**គ.១.៥. ការអនុវត្តថវិកាប្រចាំឆ្នាំរបស់មណ្ឌលថែទាំកុមារ÷** រដ្ឋបាលរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់អនុវត្តមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារ ដែលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដែលទ្រទ្រង់ដោយប្រភពថវិការដ្ឋបាលរាជធានី ខេត្តសាមី ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**គ.១.៦. ការអនុវត្តថវិកាសម្រាប់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល÷** រដ្ឋបាលរាជធានី ខេត្ត ជាអាណាប័កដើមខ្សែ មានភារកិច្ច និងទទួលខុសត្រូវលើការអនុវត្តថវិកាប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ដោយមានមន្ទីរសុខាភិបាល និងទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលជាអង្គភាពថវិកា និងអង្គភាពដទៃទៀតក្រោមឱវាទមន្ទីរសុខាភិបាល ជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមខ្លឹមសារនៃប្រកាសអន្តរក្រសួងលេខ ១៨២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល និងសារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្តសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល។

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសកំពុងអនុវត្ត ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសបន្ទាប់ ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១៥ នៃខែ នាចុងត្រីមាសនីមួយៗ ដើម្បីទុកពេលវេលាឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បូកសរុបរួចផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី២០ នៃខែ នាចុងត្រីមាសនីមួយៗ តាមតារាងឧបសម្ព័ន្ធ “ឆ១” ដល់ “ឆ៤”។

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន។

**គ.១.៧. ការអនុវត្តថវិកាប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅរាជធានី ខេត្ត ÷**

រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តថវិកាចំណាយគាំទ្រសកម្មភាពការងាររបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដែលបានគ្រោងក្នុងសៀវភៅថវិកាឆ្នាំ២០២៤ តាមមុខសញ្ញាចំណាយ មានជាអាទិ៍ចំណាយរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងសិក្ខាសាលា និងចំណាយប្រាក់បេសកកម្ម តាមគោលការណ៍ដូចខាងក្រោម÷

- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដែលមានអភិបាល ឬអភិបាលរងរាជធានី ខេត្ត ជាប្រធាន ដោយមាននាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្តជាសេនាធិការ ត្រូវលើកសំណើអនុវត្តចំណាយថវិកាតាមផែនការសកម្មភាពប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ដោយអនុលោមតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា។

- ទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវសហការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រមូលលិខិតឯកសារយុត្តិការ និងសក្ខីបត្រចំណាយលើសកម្មភាពខាងលើ ជាមូលដ្ឋានសម្រាប់រដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័ក បោះផ្សាយអាណត្តិទូទាត់ថវិកានេះ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**គ.១.៨. ការអនុវត្តកញ្ចប់ថវិកាសម្រាប់មុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ÷** រដ្ឋបាលក្រុង ស្រុក ជាអាណាប័កដើមខ្សែ និងរដ្ឋបាលខណ្ឌជាអាណាប័កផ្ទេរសិទ្ធិ មានភារកិច្ច និងទទួលខុសត្រូវ លើការអនុវត្តនីតិវិធីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដោយមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ដោយអនុវត្តស្របតាមខ្លឹមសារនៃប្រកាសអន្តរក្រសួងលេខ ៥២១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឲ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំ កុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ រហូតមានប្រកាសថ្មីមកជំនួសចូលជាធរមាន។

**គ.១.៩** រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តថវិកាការិយាល័យជំនាញទាំង ២០វិស័យ ដែលធ្វើសមាហរណកម្មចូលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដោយអនុវត្តតាមគោលការណ៍ណែនាំដែលមានជាធរមាន។ ម្យ៉ាងទៀតការចំណាយថវិកា ៣០លានរៀល សម្រាប់គាំទ្រដំណើរការប្រតិបត្តិការរដ្ឋបាលរបស់ការិយាល័យអប់រំ យុវជន និងកីឡា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជន៍ជូន ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម÷

១-រដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនត្រូវយកថវិកាចំនួន ៣០លានរៀល ដែលបានវិភាជន៍ជូន រួមបញ្ចូលជាមួយថវិកាការិយាល័យជំនាញ២០វិស័យ ទៅគ្រោង ឬចំណាយគាំទ្រការិយាល័យផ្សេងទៀតក្រៅពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ នោះទេ។ មុខសញ្ញាចំណាយថវិកា ៣០លានរៀលនេះ សម្រាប់តែដំណើរការប្រតិបត្តិការរដ្ឋបាលក្នុងការិយាល័យ និងការចុះត្រួតពិនិត្យតាមសាលារៀនរបស់បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡា ក្នុងរង្វង់ដែនដីរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី។

២-បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បំពេញបេសកកម្មចុះត្រួតពិនិត្យតាមសាលារៀនក្នុងរង្វង់ដែនដីរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់ជូនប្រាក់បេសកកម្មចំនួន ៤ម៉ឺនរៀល ក្នុងម្នាក់ ក្នុងមួយថ្ងៃ ដោយត្រូវកត់ត្រាមុខសញ្ញាចំណាយក្នុងអនុគណនី ៦១១២៨ (សោហ៊ុយក្នុងប្រទេសផ្សេងៗ)។

៣-រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទើបបង្កើតថ្មី ត្រូវបើកផ្តល់ចំណាយថវិកាប្រតិបត្តិការរដ្ឋបាលក្នុងការិយាល័យ និងចំណាយប្រាក់បេសកកម្មចុះពិនិត្យតាមសាលារៀន ជូនបុគ្គលិកអប់រំដែលបម្រើការងារបណ្តោះអាសន្ននៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដែលមានឯកសារបញ្ជាក់ឈ្មោះបុគ្គលិកតាមនីតិវិធីរដ្ឋបាលជាធរមាន។

**គ.១.១០.** រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តចំណាយថវិកា និងមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ផ្តល់ការគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការសិក្សាគម្រោងឲ្យបានទាន់ពេលវេលា និងប្រកបដោយគុណភាព ដើម្បីជំរុញឲ្យរដ្ឋបាលឃុំ សង្កាត់ អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ចំពោះគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ នៅដើមឆ្នាំថវិកា ស្របតាមខ្លឹមសារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ ស្តីពីការពន្លឿនកិច្ចលទ្ធកម្មសំណង់របស់រដ្ឋបាលឃុំ សង្កាត់។

**គ.១.១១.នីតិវិធីចំណាយថវិកាសេវាអនាម័យបរិស្ថាន និងសេវាសង្គម របស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់ឆ្នាំ២០២៤**

- នីតិវិធីអនុវត្តចំណាយថវិកាសេវាអនាម័យបរិស្ថាន របស់រដ្ឋបាលក្រុង ស្រុក ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសអន្តរក្រសួង លេខ០៧៣ ប្រកប.ស្ថ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រង សំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រហូតមានសេចក្តីណែនាំរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃមកជំនួសចូលជាធរមាន។

- នីតិវិធីអនុវត្តចំណាយថវិកាសេវាសង្គមរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវអនុវត្តតាមនីតិវិធី និងគោលការណ៍ហិរញ្ញវត្ថុដែលធ្លាប់អនុវត្តនាឆ្នាំកន្លងមក រហូតមានសេចក្តីណែនាំរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ មកជំនួសចូលជាធរមាន។

**គ.១.១២.ចំណាយមិនបានគ្រោងទុក÷** អំពីឥណទាន (ចំណាយមិនបានគ្រោងទុកជំពូក៦៩) រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មិនអាចអនុវត្តចំណាយដោយផ្ទាល់បានទេ ការបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀតតាមតម្រូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសអាទិភាពសម្រាប់តម្រូវការចំណាយប្រាក់បៀវត្ស និងចំណាយការងារអភិវឌ្ឍន៍ជាគុណប្រយោជន៍ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម÷

- រដ្ឋបាលរាជធានី ខេត្ត នៅពេលមានតម្រូវការចំណាយជំពូកនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវលើកគម្រោង និងធ្វើនិយ័តកម្មឥណទានឆ្លងការអនុម័តពីក្រុមប្រឹក្សា ដោយអនុលោមតាមប្រកាសលេខ ១០៨ សហវ.ប្រក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត។

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅពេលមានតម្រូវការចំណាយជំពូកនេះ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកគម្រោង និងធ្វើនិយ័តកម្មឥណទានឆ្លងការអនុម័តពីក្រុមប្រឹក្សា បន្ទាប់មកត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលរាជធានី ខេត្តសាមី។

- រដ្ឋបាលឃុំ សង្កាត់ នៅពេលមានតម្រូវការចំណាយជំពូកនេះ មេឃុំ ចៅសង្កាត់ត្រូវលើកគម្រោង និងធ្វើនិយ័តកម្មឥណទានថវិកា ស្នើសុំការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សាឃុំ សង្កាត់ រួចបញ្ជូនទៅអភិបាលនៃគណៈអភិបាលខេត្តដើម្បីត្រួតពិនិត្យ និងបញ្ជាក់អនុលោមភាព។

**គ.២.ការកែតម្រូវគម្រោងថវិកា**

យោងប្រការ៤២ ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឱ្យលេចចេញនូវឱនភាព រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវម្ចាស់ការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាងដើម្បីធានាតុល្យភាពថវិកាឡើងវិញ។

នៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានកើនលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបានអនុម័ត ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ឬធ្វើនិយ័តកម្មទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅតាមកម្រិតចំណូលលើសដែលបានបញ្ជិកា។ នៅដំណាច់ឆ្នាំថវិកា អតិរេកថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅថវិកាឆ្នាំខាងមុខ។ ការប្រើប្រាស់មូលនិធិនេះ ត្រូវគ្រោងឥណទានថវិកាទៅតាមរដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**គ.៣.ការបង្វែរឥណទាន**

ការបង្វែរ (និយ័តភាព) ឥណទានត្រូវបានអនុញ្ញាតឱ្យអនុវត្តចាប់ពីត្រីមាសទី២។ ក្នុងករណីមានការចាំបាច់និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយ ពីគណនីមួយ ទៅគណនីមួយ និងពីជំពូកមួយទៅជំពូកមួយផ្សេងទៀតនោះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវស្នើនិយ័តភាពដូចខាងក្រោម÷

**គ.៣.១. រដ្ឋបាលរាជធានី ខេត្ត**

រដ្ឋបាលរាជធានី ខេត្ត អាចធ្វើនិយ័តភាពចាប់ពីត្រីមាសទី២ ដោយអនុលោមតាមប្រកាសលេខ ១០៨ សហវ.ប្រក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត។

**គ.៣.២. រដ្ឋបាលខណ្ឌ**

រដ្ឋបាលខណ្ឌដែលជាអង្គភាពថវិកា និងមានការិយាល័យផែនការ និងហិរញ្ញវត្ថុ ដែលជាអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ អាចធ្វើនិយ័តភាពឥណទានថវិកាស្របតាមនីតិវិធី និងទទួលបានប្រតិភូកម្មអំណាចដូចខាងក្រោម÷

- និយ័តភាពឥណទានថវិកាក្នុងចង្កោមសកម្មភាពតែមួយនៃអនុកម្មវិធីតែមួយ និងការធ្វើប្រតិភូអំណាច÷
  - ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលរាជធានី។ ប៉ុន្តែជំពូក៦៤ (ចំណាយបន្ទុកបុគ្គលិក) មិនត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានចេញឡើយ។
  - រដ្ឋបាលខណ្ឌសាមី ត្រូវបានប្រតិភូកម្មអំណាចក្នុងការធ្វើនិយ័តភាពឥណទានពីអនុគណនីមួយទៅអនុគណនីមួយទៀត, ពីគណនីមួយទៅគណនីមួយទៀតក្នុងជំពូកតែមួយនៃចង្កោមសកម្មភាពតែមួយ (លើកលែងអនុគណនី៦១០៥១ ដល់អនុគណនី៦១០៥៧ នៃជំពូក៦១ ជំពូក២០ និងជំពូក២១ នៃចំណាយមូលធន) ដោយត្រូវធ្វើសំណើសុំការអនុម័តយល់ព្រមពីក្រុមប្រឹក្សាខណ្ឌ និងមានសេចក្តីសម្រេចយល់ព្រមពីអភិបាលនៃគណៈអភិបាលរាជធានី។ សេចក្តីសម្រេចនិយ័តភាពនេះ ត្រូវចម្លងជូនអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគាររាជធានី។
- និយ័តភាពឥណទានថវិកាពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀតនៃអនុកម្មវិធីតែមួយ និងការធ្វើប្រតិភូកម្មអំណាច÷
  - ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយទៀត, ពីជំពូកមួយទៅជំពូកមួយទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលរាជធានី។ ប៉ុន្តែជំពូក៦៤ (ចំណាយបន្ទុកបុគ្គលិក) មិនត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានចេញឡើយ។
  - រដ្ឋបាលខណ្ឌសាមី ត្រូវបានប្រតិភូកម្មអំណាចក្នុងការធ្វើនិយ័តភាពឥណទានពីអនុគណនីមួយទៅអនុគណនីមួយទៀតក្នុងគណនីតែមួយ (លើកលែងអនុគណនី៦១០៥១ ដល់អនុគណនី៦១០៥៧ នៃជំពូក៦១ ជំពូក២០ និងជំពូក២១ នៃចំណាយមូលធន) ដោយត្រូវធ្វើសំណើសុំការអនុម័តយល់ព្រមពីក្រុមប្រឹក្សាខណ្ឌ និងមានសេចក្តីសម្រេចយល់ព្រមពីអភិបាលនៃគណៈអភិបាលរាជធានី។ សេចក្តីសម្រេចនិយ័តភាពនេះ ត្រូវចម្លងជូនអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគាររាជធានី។
- និយ័តភាពឥណទានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត÷
  - ការធ្វើនិយ័តភាពឥណទានពីកម្មវិធីមួយទៅកម្មវិធីមួយទៀត រដ្ឋបាលខណ្ឌត្រូវលើកសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលរាជធានី ដោយភ្ជាប់មកជាមួយនូវ របាយការណ៍ចំណាយជាក់ស្តែង ដែលបានអនុវត្តកន្លងមក និងគម្រោងប៉ាន់ស្មានចំណាយលម្អិតដល់ដំណាច់ឆ្នាំ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព។

ជាមួយគ្នានេះ សម្រាប់រដ្ឋបាលខណ្ឌដែលអនុវត្តថវិកាកម្មវិធី រាល់ការនិយ័តភាពថវិកានៃអនុគណនី ៦០០២១ ៦០០៥១ និង៦០០៥៤ នៃជំពូក៦០, អនុគណនី ៦៤០៣៣ និង៦៤០៤១ នៃជំពូក ៦៤, និងអនុគណនី ៦២០២៤ និង៦២០២៨ នៃជំពូក ៦២ ត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេច។

**គ.៣.៣. រដ្ឋបាលក្រុង ស្រុក**

រដ្ឋបាលក្រុង ស្រុក អាចធ្វើនិយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយទៀត ពីគណនីមួយ ទៅគណនីមួយទៀតក្នុងជំពូកតែមួយ (លើកលែងអនុគណនី៦១០៥១ ដល់អនុគណនី៦១០៥៧ នៃជំពូក៦១ ជំពូក២០ និងជំពូក២១ នៃចំណាយមូលធន) ដោយត្រូវធ្វើសំណើសុំការអនុម័ត និងមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ព្រមទាំងមានការយល់ព្រមពីអភិបាលនៃគណៈអភិបាលខេត្ត (មិនអនុញ្ញាតការធ្វើនិយ័តកម្មថវិកាពីចំណាយអភិវឌ្ឍន៍ទៅបម្រើឱ្យចំណាយរដ្ឋបាលដាច់ខាត)។ ការធ្វើនិយ័តភាពថវិកា ពីជំពូកមួយទៅជំពូកមួយទៀតអភិបាលនៃគណៈអភិបាលក្រុង ស្រុក ត្រូវធ្វើការស្នើសុំការអនុម័តពីក្រុមប្រឹក្សា ក្រុង ស្រុក និងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋបាលខេត្តសាមី ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណាយជាក់ស្តែងដែលបានអនុវត្តកន្លងមក និងគម្រោងប៉ាន់ស្មានចំណាយលម្អិតដល់ដំណាច់ឆ្នាំ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព។ សម្រាប់ការធ្វើនិយ័តភាពថវិកាពីជំពូក៦៤(ចំណាយបន្ទុកបុគ្គលិក) អាចធ្វើទៅបានក្នុងរង្វង់ជំពូក៦៤តែប៉ុណ្ណោះ។

**គ.៣.៤. រដ្ឋបាលឃុំ សង្កាត់**

